សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ROYAL UNIVERSITY OF PHNOM PENH

# ឯកសារគោលស្តីពី
# សិទ្ធិទទួលព័ត៌មាន




ឯកសារនេះត្រូវបានចងក្រងឡើង ដើម្បីប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលស្តីពី "សិទ្ធិទទួលព័ត៌មាន"។

ឧបត្ថម្ភដោយ៖

SWEDEN

UNESCO
United Nations Educational, Scientific and Cultural Organization
Organisation des Nations Unies pour l'éducation, la science et la culture

វិទ្យាស្ថានសារគមនាគមន៍កម្ពុជា
Cambodia Communication Institute
2016

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
វិទ្យាស្ថានសារគមនាគមន៍កម្ពុជា

# ឯកសារគោល
# ស្តីពី សិទ្ធិទទួលព័ត៌មាន

ក្រោមគម្រោងសេចក្តីព្រាងច្បាប់ "សិទ្ធិទទួលព័ត៌មាន"

Working Towards an Access to Information Law in Cambodia:

Bridging the Government and Citizens for Participatory Law-Making

Sub-Project:

Increasing Demand for Access to Information from the Media Sector

គម្រោងនេះបានទទួលការឧបត្ថម្ភដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA)តាមរយៈអង្គការ UNESCO ភ្នំពេញ

ខែសីហា ឆ្នាំ២០១៦

# មាតិកា

កម្មវិធីបង្រៀន....................i
ឯកសារយោង....................v
ជំពូក ១ : ប្រព័ន្ធច្បាប់និងតុលាការកម្ពុជា....................១
ជំពូក ២ : រដ្ឋធម្មនុញ្ញកម្ពុជា និង សិទ្ធិទទួលព័ត៌មាន....................៤
ជំពូក ៣ : គោលការណ៍អន្តរជាតិនៃសិទ្ធិទទួលព័ត៌មាន (១)....................៧
ជំពូក ៤ : គោលការណ៍អន្តរជាតិនៃសិទ្ធិទទួលព័ត៌មាន (២)....................១០
ជំពូក ៥ : ការត្រួតពិនិត្យច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅកម្ពុជា (១)....................១៦
ជំពូក ៦ : ការត្រួតពិនិត្យច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅកម្ពុជា (២)....................១៩
ឧបសម្ព័ន្ធ៖....................២២
ឯកសារយោង....................២២

# កម្មវិធីបង្រៀន

| វគ្គ | ប្រធានបទ | ឯកសារយោង |
|---|---|---|
| ១ | ជំពូកទី ១៖<br>ប្រព័ន្ធច្បាប់និង<br>តុលាការ កម្ពុជា | ១. អត្ថបទ៖ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់និង តុលាការ ប្រទេសកម្ពុជា ដោយ គង់ ផល្លៈ<br>២. សៀវភៅ៖ សេចក្តីផ្តើមនៃនីតិកម្ពុជា (Kas' s Publication) |
| ២ | ជំពូកទី ២៖<br>រដ្ឋធម្មនុញ្ញកម្ពុជា និង សិទ្ធិ<br>ទទួលព័ត៌មាន | ៣.រដ្ឋធម្មនុញ្ញកម្ពុជា<br>៤.សន្ធិសញ្ញាអន្តរជាតិដែលផ្តល់សច្ចាប័នដោយកម្ពុជា |
| ៣ | ជំពូកទី ៣៖<br><br>គោលការណ៍ អន្តរជាតិ នៃសិទ្ធិ<br>ទទួលព័ត៌មាន (១) | ៥. អង្គការ DIHR, សេចក្តីផ្តើមនៃការបើកចំហ និង សិទ្ធិទទួលព័ត៌មាន<br>៦. អង្គការ មាត្រា ១៩, សិទ្ធិរបស់សាធារណៈជន ដែលត្រូវដឹង, គោលការណ៍ នៃច្បាប់អំពីសិទ្ធិទទួល ព័ត៌មាន<br>៧.អង្គការ API, មេរៀនទី ៨៖ គោលការណ៍ទាំង ៩ ស្តីអំពីសិទ្ធិទទួលព័ត៌មាន(ខ្មែរ)<br>៨. Toby Mendel, សេរីភាពព័ត៌មាន, ការអង្កេត ប្រៀប ធៀបផ្នែកច្បាប់ (អង់គ្លេស ខ្មែរ), Unesco |
| ៤ | ជំពូកទី ៤៖ គោលការណ៍អន្តរ<br>ជាតិ នៃសិទ្ធិទទួលព័ត៌មាន<br>(២) | ៥. អង្គការ DIHR, សេចក្តីផ្តើមនៃការបើកចំហ និង សិទ្ធិទទួលព័ត៌មាន<br>៦. អង្គការ មាត្រា ១៩, សិទ្ធិរបស់សាធារណៈជន ដែលត្រូវដឹង, គោលការណ៍នៃ ច្បាប់ អំពីសិទ្ធិទទួល ព័ត៌មាន<br>៧.អង្គការ API, មេរៀនទី ៨៖ គោលការណ៍ទាំង ៩ ស្តីអំពីសិទ្ធិទទួល |

| វគ្គ | ប្រធានបទ | ឯកសារយោង |
| --- | --- | --- |
| | | ព័ត៌មាន(ខ្មែរ)<br>៨. Toby Mendel, សេរីភាពព័ត៌មាន, ការអង្កេត ប្រៀបធៀបផ្នែកច្បាប់ (អង់គ្លេស ខ្មែរ), Unesco |
| ៥ | ជំពូកទី ៥៖ ការពិនិត្យនិងការវិភាគ ច្បាប់ដែលមានចែងអំពីសិទ្ធិទទួលព័ត៌មាន នៅកម្ពុជា (១) | ៩.អង្គការ API, របកគំហើញនៃការពិនិត្យនិងការវិភាគ ឯកសារច្បាប់និងអនុក្រិត្យដែលមានចែង អំពីសិទ្ធិ ទទួលព័ត៌មាននិងការ បើកចំហព័ត៌មាន៖ អប់រំ សុខភាពនិងឱសថ, សេដ្ឋកិច្ច និងវិនិយោគ, ការងារ, បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, រិមជ្ឈការ និង វិសហមជ្ឈការ, កសិកម្ម ជលផល និង រុក្ខប្រមាញ់, ពិការភាព និង រដ្ឋបាលសាធារណៈ<br>១០. ក្របខណ្ឌគោលនយោបាយ ស្តីអំពីសិទ្ធិទទួលព័ត៌មាន (សេចក្តីព្រាង) |
| ៦ | ជំពូកទី ៦៖ ការពិនិត្យនិងការវិភាគ ច្បាប់ដែលមានចែងអំពីសិទ្ធិទទួលព័ត៌មាន នៅកម្ពុជា (២) | ៩.អង្គការ API, របកគំហើញនៃការពិនិត្យនិងការវិភាគ ឯកសារច្បាប់និងអនុក្រិត្យដែលមានចែង អំពីសិទ្ធិ ទទួលព័ត៌មាននិងការ បើកចំហព័ត៌មាន៖ អប់រំ សុខភាពនិងឱសថ, សេដ្ឋកិច្ច និងវិនិយោគ, ការងារ, បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, វិមជ្ឈការ និង វិសហមជ្ឈការ, កសិកម្ម ជលផល និង រុក្ខប្រមាញ់, ពិការភាព និង រដ្ឋបាលសាធារណៈ<br>១០. ក្របខណ្ឌគោលនយោបាយស្តីអំពីសិទ្ធិទទួល ព័ត៌មាន (សេចក្តីព្រាង) |

**វិធីសាស្ត្រនៃការបង្រៀន៖**លំហាត់នៃការណែនាំខ្លួន វិធីសាស្ត្រសូក្រាត ការពិភាក្សាជាក្រុម ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

**វិធីសាស្ត្រនៃការវាយតម្លៃ៖**

ពិន្ទុសរុប ១០០ % និងត្រូវបែងចែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

| | |
|---|---|
| ១. ការចូលរួម | ២0% |
| ២. គម្រោងស្រាវជ្រាវទី១ | ៤0% |
| ៣.គម្រោងស្រាវជ្រាវទី ២ | ៤0% |

**វិធាននៃការវាយតម្លៃ៖**

១. វិធាននៃវត្តមាន និង ការចូលរួម៖

១.១ ការចូលរួមគឺជាកាតព្វកិច្ច។ ការចូលរួមសំដៅលើ សកម្មភាពក្នុងថ្នាក់ ដូចជា ការចូលរួមយ៉ាង សកម្មក្នុងការពិភាក្សា និងការងារសាលាដែលចាត់ តាំងឲ្យធ្វើ (ដូចជា ការស្រាវជ្រាវ ការធ្វើបទបង្ហាញខ្លីៗ សំណួរសរសេរ ជាដើម)។ ដើម្បីទទួលបាន ២0% និស្សិតទាំងអស់ត្រូវចូលរួមគ្រប់ សកម្មភាពក្នុងថ្នាក់ដែលចាត់តាំងឲ្យធ្វើ។ ការខកខានមិនបានចូលរួមនឹងត្រូវ ដកពិន្ទុ។

២. វិធាននៃគម្រោងស្រាវជ្រាវទី ១៖

២.១ គម្រោងស្រាវជ្រាវអាចធ្វើជាក្រុមឬធ្វើតែម្នាក់ឯង។ ប្រធានបទត្រូវទាក់ទងអំពីសិទ្ធិទទួលព័ត៌មាន។ និស្សិតត្រូវរៀបចំផែនការស្រាវជ្រាវ (ពិន្ទុ ១០ %)។

២.២ និស្សិតត្រូវធ្វើបទបង្ហាញ ក្នុងថ្នាក់ ហើយការវាយតម្លៃនៃបទបង្ហាញ គឺផ្អែកលើលក្ខណៈវិនិច្ឆ័យ ខាងក្រោម៖

| ខ្លឹមសារនៃប្រធានបទ<br>១0% | ការធ្វើបទបង្ហាញ<br>១0% | សំណួរ និងចម្លើយ<br>១0% |
|---|---|---|
| ចំណេះដឹងលើប្រធានបទ<br>ចំណាប់អារម្មណ៍របស់ អ្នកអានច្បាស់លាស់មានការវិភាគ ដែលមានហេតុផល | ការរៀបចំបទបង្ហាញ<br>ការធ្វើបទបង្ហាញ<br>ជំនឿទុកចិត្ត<br>ការត្រៀមខ្លួនបានល្អ | លទ្ធភាពនៃការស្តាប់<br>សំណួរ<br>លទ្ធភាពនៃការឆ្លើយ |

២.៣ បទបង្ហាញត្រូវជាក្រដាស និងជាឯកសារអេលិកត្រូនិកត្រូវប្រគល់ ជូន សាស្ត្រាចារ្យ នៃ ថ្ងៃធ្វើបទបង្ហាញ។

៣. វិធាននៃគម្រោងសិក្សាទី ២៖

៣.១ វិធានទូទៅនៃគម្រោងស្រាវជ្រាវទី១ក៏ត្រូវអនុវត្តក្នុងគម្រោងស្រាវ ជ្រាវទី២ ដែរ។

៣.២ ការវាយតម្លៃលើរបាយការណ៍ស្រាវជ្រាវ ផ្អែកលើខ្លឹមសារ នៃប្រធានបទ ចំណាប់អារម្មណ៍របស់អ្នកអាន ការវិភាគដែលមានហេតុផល ការច្នៃប្រឌិត និងគោរពតាមទម្រង់ និងវិធាន នៃការសរសេរ របស់*CCI*។

៤. វិធាននៃការលួចចម្លងស្នាដៃអ្នកដទៃនិងការបន្លំ៖

៤.១ ការលួចចម្លងស្នាដៃអ្នកដទៃគឺជាបទល្មើសផ្នែកសិក្សាហើយត្រូវហាម ឃាត់ដាច់ខាត និងជាកម្មវត្ថុនៃការដកពិន្ទុ។

៤.២ ការលួចបន្លំត្រូវហាមឃាត់និងជាកម្មវត្ថុនៃការដកពិន្ទុ។ ការកែប្រែ ឬចម្លងស្នាដៃ អ្នកណាម្នាក់ ត្រូវចាត់ទុកជាការបន្លំនៅក្នុងថ្នាក់នេះ។

**ឯកសារយោង៖**


១. អត្ថបទ៖ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់និងតុលាការប្រទេសកម្ពុជា ដោយ គង់ ផល្លៈ

២. សៀវភៅ៖ សេចក្តីផ្តើមនៃនីតិកម្ពុជា ( Kas' s Publication )

៣.រដ្ឋធម្មនុញ្ញកម្ពុជា

៤.សន្ធិសញ្ញាអន្តរជាតិដែលផ្តល់សច្ចាប័នដោយកម្ពុជា

៥. អង្គការ DIHR, សេចក្តីផ្តើមនៃការបើកចំហ និងសិទ្ធិទទួលព័ត៌មាន

៦. អង្គការ មាត្រា ១៩, សិទ្ធិរបស់សាធារណៈជនដែលត្រូវដឹង, គោលការណ៍នៃ ច្បាប់ អំពីសិទ្ធិទទួលព័ត៌មាន

៧.អង្គការ API, មេរៀនទី ៨៖ គោលការណ៍ទាំង ៩ស្តីអំពីសិទ្ធិទទួលព័ត៌មាន(ខ្មែរ)

៨. Toby Mendel, សេរីភាពព័ត៌មាន, ការអង្កេតប្រៀបធៀបផ្នែកច្បាប់ (អង់គ្លេស ខ្មែរ), Unesco

៩.អង្គការ API, របកគំហើញនៃការពិនិត្យនិងការវិភាគឯកសារច្បាប់និងអនុក្រិត្យដែលមាន ចែងអំពីសិទ្ធិទទួលព័ត៌មាននិងការបើកចំហព័ត៌មាន៖ អប់រំ សុខភាពនិងឪសថ, សេដ្ឋកិច្ច និងវិនិយោគ, ការងារ, បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, រិមជ្ឈការនិង វិសហមជ្ឈការ, កសិកម្មជលផល និងរុក្ខប្រមាញ់, ពិការភាព និងរដ្ឋបាលសាធារណៈ

១០. ក្របខណ្ឌគោលនយោបាយស្តីអំពីសិទ្ធិទទួលព័ត៌មាន (សេចក្តីព្រាង)

# ជំពូកទី ១
# ប្រព័ន្ធច្បាប់និងតុលាការកម្ពុជា

## ក. គោលបំណង

ណែនាំនិស្សិតអំពីចំណេះដឹងមូលដ្ឋាននៃច្បាប់កម្ពុជានិងប្រព័ន្ធដោះស្រាយវិវាទនិងទំនាក់ទំនងរវាងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ខ. លទ្ធផលនៃការសិក្សា

- ការយល់ដឹងអំពីប្រព័ន្ធច្បាប់និង ប្រភពច្បាប់ កម្ពុជា
- ការយល់ដឹងអំពីប្រព័ន្ធដោះស្រាយវិវាទនៅ កម្ពុជា
- ការយល់ដឹងអំពីទំនាក់ទំនងរវាងច្បាប់ជាតិនិងអន្តរជាតិ

## គ. មាតិកា

១. ការស្វែងយល់អំពីប្រព័ន្ធច្បាប់កម្ពុជា
២. ប្រភពនៃច្បាប់កម្ពុជា
៣. ទំនាក់ទំនងរវាងច្បាប់ជាតិនិងអន្តរជាតិ
៤. ប្រព័ន្ធដោះស្រាយវិវាទនៅកម្ពុជា
៥. ឈប់ និងត្រួតពិនិត្យ

## ឃ. វិធីសាស្ត្រនៃការបង្រៀន

- លំហាត់នៃការណែនាំខ្លួន
- វិធីសាស្ត្រសូក្រាត
- ការពិភាក្សាជាក្រុម
- ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

## ង. ការវាយតម្លៃ

- វិធីសាស្ត្រនៃការគ្រប់គ្រងចំណេះដឹង

## ច. ឯកសារ

១. អត្ថបទ៖ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់និងតុលាការប្រទេសកម្ពុជា ដោយ គង់ ផល្លៈ

២. សៀវភៅ៖ សេចក្តីផ្តើមនៃនីតិកម្ពុជា ( Kas' s Publication )

## ឆ. ការសង្ខេបខ្លឹមសារមេរៀន

១. ការស្វែងយល់អំពីប្រព័ន្ធច្បាប់កម្ពុជា

- ប្រវត្តិនៃការវិវត្តច្បាប់នៅកម្ពុជា
- ប្រព័ន្ធច្បាប់ធំៗពីរក្នុងពិភពលោក៖ ខំម៉ិនឡស៍ និង ស៊ីវិលឡស៍
- ប្រព័ន្ធច្បាប់កម្ពុជា៖ ប្រព័ន្ធកូនកាត់ (បវេណីខំម៉ិនឡស៍ និង ស៊ីវិលឡស៍ )
- ការស្វែងរកច្បាប់កម្ពុជា

២. ប្រភពនៃច្បាប់កម្ពុជា

ប្រភពច្បាប់ជាតិ

- រដ្ឋធម្មនុញ្ញ
- ច្បាប់
- ព្រះរាជក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ
- ដីកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- សេចក្តីជូនដំណឹង
- ទំនៀមទម្លាប់ ឬការអនុវត្ត
- សេចក្តីសម្រេចតុលាការ
- សេចក្តីបង្គាប់អាជ្ញាកណ្តាល

ប្រភពច្បាប់អន្តរជាតិ

- សន្ធិសញ្ញាអន្តរជាតិ អនុសញ្ញា និងកិច្ចព្រមព្រៀង ដែលផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា

៣. ទំនាក់ទំនងរវាងច្បាប់ជាតិនិងអន្តរជាតិ

- ទ្រឹស្តីឯកនិយម
- ទ្រឹស្តីទ្វេនិយម
- ប្រទេសកម្ពុជាប្រកាន់យករបបទ្វេនិយម

៤. ប្រព័ន្ធដោះស្រាយវិវាទនៅកម្ពុជា

- តុលាការះ សាលាដំបូង សាលាឧទ្ធរណ៍ តុលាការកំពូល
- ការដោះស្រាយវិវាទក្រៅតុលាការះ ការចរចា ការសម្របសម្រួល ការផ្សះផ្សា និងអាជ្ញាកណ្តាល

## ជ. សំណួរវាយតម្លៃការយល់ដឹង

- តើប្រទេសកម្ពុជាប្រកាន់ប្រព័ន្ធច្បាប់អ្វី ?
- តើទ្រឹស្តីឯកនិយមនិងទ្វេនិយមខុសគ្នាដូចម្តេច ?
- តើច្បាប់អន្តរជាតិក្លាយជាច្បាប់ជាតិដោយរបៀបណា ?
- តើអ្នកយកចំណេះដឹងពីប្រព័ន្ធដោះស្រាយវិវាទមកអនុវត្ត ចំពោះសិទ្ធិទទួលព័ត៌មានដូចម្តេច ?
- ចូរសរសេរអត្ថបទធម្មតានិងខ្លីដែលពន្យល់សាធារណៈជន អំពីប្រព័ន្ធច្បាប់កម្ពុជា។

# ជំពូកទី ២
# រដ្ឋធម្មនុញ្ញកម្ពុជា និង សិទ្ធិទទួលព័ត៌មាន

## ក. គោលបំណង

ណែនាំនិស្សិតអំពីចំណេះដឹងមូលដ្ឋានអំពីសិទ្ធិមនុស្ស និងច្បាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា ។

## ខ. លទ្ធផលនៃការសិក្សា

- សិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋ
- ច្បាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា
- បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិទទួលព័ត៌មាននៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

## គ. មាតិការ

១. ទស្សនាទាននៃសិទ្ធិមនុស្ស

២. សិទ្ធិនិងករណីកិច្ចរបស់រដ្ឋ

៣. រដ្ឋធម្មនុញ្ញនិងសិទ្ធិមនុស្ស

៤. អនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលផ្តល់ សច្ចាប័នដោយកម្ពុជា

៥. សិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

៦. បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិទទួលព័ត៌មាននៅក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់អន្តរជាតិ

៧. ឈប់ និងត្រួតពិនិត្យ

## ឃ. វិធីសាស្ត្រនៃការបង្រៀន

- លំហាត់នៃការណែនាំខ្លួន
- វិធីសាស្ត្រសូក្រាត
- ការពិភាក្សាជាក្រុម
- ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

## ង. ការវាយតម្លៃ

វិធីសាស្ត្រនៃការគ្រប់គ្រងចំណេះដឹង

## ច. ឯកសារ

៣. រដ្ឋធម្មនុញ្ញកម្ពុជា

៤. សន្ធិសញ្ញាអន្តរជាតិដែលផ្តល់សច្ចាប័នដោយកម្ពុជា

## ឆ. ការសង្ខេបខ្លឹមសារមេរៀន

១. ទស្សនាទាននៃសិទ្ធិមនុស្ស

- និយមន័យសិទ្ធិមនុស្ស
- គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់
- កាតព្វកិច្ចរបស់រដ្ឋពាក់ព័ន្ធសន្ធិសញ្ញាអន្តរជាតិ សិទ្ធិមនុស្សដែលបានផ្តល់សច្ចាប័ន
- ចំណាត់ថ្នាក់សិទ្ធិមនុស្ស៖ សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច សិទ្ធិវប្បធម៌ និង សិទ្ធិសមូហភាព

២. សិទ្ធិនិងករណីកិច្ចរបស់រដ្ឋ

- គោលការណ៍ បី៖ គោរព ការពារ និង អនុវត្ត

៣. រដ្ឋធម្មនុញ្ញនិងសិទ្ធិមនុស្ស

- មាត្រា ៣១នៃរដ្ឋធម្មនុញ្ញកម្ពុជា

៤. អនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលផ្តល់ សច្ចាប័នដោយកម្ពុជា

- កតិកាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ
- កតិកាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌
- អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម
- អនុសញ្ញាស្តីពីការលុបបំបាត់រាលើទម្រង់រើសអើងគ្រប់ប្រភេទលើស្ត្រី
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើង ប្រឆាំងពូជសាសន៍

៥. សិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

- សិទ្ធិពលរដ្ឋ៖ មាត្រា ៣១ ៣៨ ៣២ ៣៣

- សិទ្ធិនយោបាយៈ មាត្រា ៣៤ ៣៥ ៣៦ ៣៧ ៤១ ៤២
- សិទ្ធិសេដ្ឋកិច្ចៈ មាត្រា ៣៥ ៣៦ ៤៤ ៣៩
- សិទ្ធិវប្បធម៌ៈ មាត្រា ៣៥ ៤៣ ៤៧
- សិទ្ធិសង្គមកិច្ចៈ មាត្រា ៣៥ ៣៩ ៤០ ៤៣ ៤៤ ៤៥ ៤៦ ៤៧ ៤៨

៦. បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិទទួលព័ត៌មាននៅក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់អន្តរជាតិ

- មាត្រា ៤១ ៣៥

## ជ. សំណួរវាយតម្លៃការយល់ដឹង

- តាមទស្សនាទាននៃសិទ្ធិមនុស្ស តើប្រទេសកម្ពុជា ប្រកាន់ទ្រឹស្តីឯកនិយមឬ ទ្វេនិយម ផ្អែកតាមមាត្រា ៣១នៃ រដ្ឋ ធម្មនុញ្ញកម្ពុជា?
- ចូរស្វែងរកច្បាប់និងប្បញ្ញត្តិកម្ពុជាពាក់ព័ន្ធនឹងសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋ-កិច្ច សិទ្ធិវប្បធម៌ និង សិទ្ធិសង្គម
- ចូររកច្បាបើនិងបទប្បញ្ញត្តិកម្ពុជាពាក់ព័ន្ធនឹងសិទ្ធិទទួលព័ត៌មាន
- ចូរសរសេរអត្ថបទធម្មតានិងខ្លីដែលពន្យល់សាធារណៈជន អំពីសិទ្ធិមនុស្សក្នុង រដ្ឋធម្មនុញ្ញកម្ពុជា។

# ជំពូកទី ៣
# គោលការណ៍អន្តរជាតិនៃសិទ្ធិទទួលព័ត៌មាន (១)

## ក. គោលបំណង

ណែនាំនិស្សិតអំពីគោលការណ៍អន្តរជាតិនៃសិទ្ធិទទួល ព័ត៌មាន

## ខ. លទ្ធផលនៃការសិក្សា

- ស្តង់ដាស្តីអំពីការបើកចំហ និងសិទ្ធិទទួលព័ត៌មាន
- គោលការណ៍អន្តរជាតិនៃសិទ្ធិទទួលព័ត៌មាន

## គ. មាតិកា

១. ស្តង់ដាស្តីអំពីការបើកចំហ និងសិទ្ធិទទួលព័ត៌មាន

២. គោលការណ៍អន្តរជាតិស្តីអំពីការបើកចំហ និងសិទ្ធិទទួល ព័ត៌មាន

៣. ស្តង់ដាអន្តរជាតិស្តីអំពីការការពារភាពឯកជននិងទិន្នន័យ បុគ្គល

៤. ស្តង់ដាអន្តរជាតិស្តីអំពីអភិបាលកិច្ចល្អនិងការប្រឆាំង អំពើពុករលួយ

៥. ឈប់និងត្រួតពិនិត្យ

## ឃ. វិធីសាស្ត្រនៃការបង្រៀន

- លំហាត់នៃការណែនាំខ្លួន
- វិធីសាស្ត្រសូក្រាត
- ការពិភាក្សាជាក្រុម
- ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

## ង. ការវាយតម្លៃ

វិធីសាស្ត្រនៃការគ្រប់គ្រងចំណេះដឹង

## ច. ឯកសារ

៥. អង្គការ DIHR, សេចក្តីផ្តើមនៃការបើកចំហ និងសិទ្ធិទទួលព័ត៌មាន

៦. អង្គការ មាត្រា ១៩, សិទ្ធិរបស់សាធារណៈជនដែលត្រូវដឹង, គោលការណ៍នៃ ច្បាប់ អំពី សិទ្ធិទទួលព័ត៌មាន

៧. អង្គការ API, មេរៀនទី ៨៖ គោលការណ៍ទាំង ៩ស្តីអំពីសិទ្ធិទទួលព័ត៌មាន(ខ្មែរ)

៨. Toby Mendel, សេរីភាពព័ត៌មាន, ការអង្កេតប្រៀបធៀបផ្នែកច្បាប់ (អង់គ្លេស ខ្មែរ), Unesco

## ឆ. ការសង្ខេបខ្លឹមសារមេរៀន

១. ស្តង់ដាស្តីអំពីការបើកចំហ និងសិទ្ធិទទួលព័ត៌មាន

- តើអ្វីទៅជាស្តង់ដាបើកចំហនិងសិទ្ធិទទួលព័ត៌មាន?
- សិទ្ធិរបស់សាធារណៈជនទាក់ទងនឹងកិច្ចការសាធារណៈ
- ការកម្រិតនៃការបើកចំហ
- ព័ត៌មានទំនើបនិងបច្ចេកវិជ្ជាទំនាក់ទំនង
- សង្គមបើកចំហ និង លំហូនៃការបើកចំហ
- ស្តង់ដានៃភាពបើកចំហនិងសិទ្ធិទទួលព័ត៌មានក្នុងប្រទេសខំមិនឡស៍ និងស៊ីវិលឡស៍
- របៀបស្វែងរកច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

២. គោលការណ៍អន្តរជាតិស្តីអំពីការបើកចំហ និងសិទ្ធិទទួល ព័ត៌មាន

- សេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា ១៩)
- ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិង សិទ្ធិប្រជាពលរដ្ឋ (មាត្រា ៩)
- អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (មាត្រា ១៣.១)
- ធម្មនុញ្ញសហគមន៍អ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស (មាត្រា ១០.១)
- សេចក្តីថ្លែងការសិទ្ធិមនុស្សរបស់សមាគមន៦អាស៊ាន (មាត្រា ២៣)
- សេចក្តីព្រាងធម្មនុញ្ញអារ៉ាប់ស្តីពីសិទ្ធិមនុស្ស (មាត្រា ៣២)

៣. ស្តង់ដាអន្តរជាតិស្តីអំពីការការពារភាពឯកជននិងទិន្នន័យ បុគ្គល

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (មាត្រា ១៧)
- ធម្មនុញ្ញសហគមន៍អ៊ឺរ៉ុបស្តីពីសិទ្ធិមនុស្ស (មាត្រា៨)

- អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (មាត្រា ១១)
- សេចក្តីថ្លែងការសិទ្ធិមនុស្សរបស់សមាគមន៦អាស៊ាន (មាត្រា ២១)

៤. ស្តង់ដាអន្តរជាតិស្តីអំពីអភិបាលកិច្ចលល្អនិងការប្រឆាំង អំពើពុករលួយ

- អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (មាត្រា ១០, ១៣)
- អនុសញ្ញាពុករលួយរបស់សហភាពអាហ្វ្រិក (មាត្រា ២, ៥, ៣, ១២, ៤)
- សេចក្តីថ្លែងការសាន់ទីយ៉ាហ្គោស្តីអំពីប្រជាធិបតេយ្យនិងទំនុកចិត្តសាធារណៈ
- គំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយនៅតំបន់អាស៊ី ប៉ាស៊ីហ្វិក ដោយ ធនាគារអាភិវឌ្ឍន៍ អាស៊ី និង អង្គការ សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍
- អនុសញ្ញារបស់អង្គការ សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ស្តីពីការស៊ីសំណូករបស់ម ន្ត្រីរាជការសាធារណៈ របស់បរទេស
- អនុសញ្ញាច្បាប់ព្រហ្មទណ្ឌរបស់សហគមន៍អ៊ឺរ៉ុបស្តីពីអំពើពុករលួយ
- អនុសញ្ញាច្បាប់រដ្ឋប្បវេណីរបស់សហគមន៍អ៊ឺរ៉ុបស្តីពីអំពើពុករលួយ

## ជ. សំណួរវាយតម្លៃការយល់ដឹង

១. ចូរសរសេរអត្ថបទធម្មតានិងខ្លីដែលពន្យល់សាធារណៈជនអំពីទស្សនាទាននៃការបើក ចំហនិងសិទ្ធិទទួលព័ត៌មាន។

២. តើយើងអាចអនុវត្តគោលការណ៍នៃការបើកចំហនិងសិទ្ធិទទួលព័ត៌មានដូចម្តេច នៅក្នុង ប្រទេសកម្ពុជា?

៣. តើប្រទេសកម្ពុជាតម្រូវឲ្យអនុវត្តស្តង់ដាអន្តរជាតិទាំងអស់ នៃសិទ្ធិទទួលព័ត៌មានដែរ ឬទេ?

# ជំពូកទី ៤
# គោលការណ៍អន្តរជាតិនៃសិទ្ធិទទួលព័ត៌មាន (២)

**ក. គោលបំណង**

ណែនាំនិស្សិតអំពីគោលការណ៍អន្តរជាតិនៃសិទ្ធិទទួល ព័ត៌មាន

**ខ. លទ្ធផលនៃការសិក្សា**

មូលដ្ឋាននៃគោលការណ៍អន្តរជាតិទាំង ៩ នៃសិទ្ធិទទួល ព័ត៌មាន

**គ. មាតិកា**

១. គោលការណ៍ទី១៖ ការបើកចំហជាអតិបរិមា
២. គោលការណ៍ទី២៖ កាតព្វកិច្ចផ្សព្វផ្សាយជាសាធារណៈ
៣. គោលការណ៍ទី៣៖ ការបើកស្ទួយរដ្ឋាភិបាលឲ្យបើកចំហ
៤. គោលការណ៍ទី៤៖ ដែនកំណត់នៃការលើកលែង
៥. គោលការណ៍ទី៥៖ ដំណើរការសម្របសម្រួលសិទ្ធិទទួល ព័ត៌មាន
៦. គោលការណ៍ទី៦៖ ការបង់ថ្លៃទទួលព័ត៌មាន
៧. គោលការណ៍ទី៧៖ កិច្ចប្រជុំបើកចំហ
៨. គោលការណ៍ទី៨៖ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ត្រូវមាន ប្រៀបជាង
៩. គោលការណ៍ទី៩៖ ការការពារប្រភពព័ត៌មាន
១០. ឈប់និងត្រួតពិនិត្យ

**ឃ. វិធីសាស្ត្រនៃការបង្រៀន**

- លំហាត់នៃការណែនាំខ្លួន
- វិធីសាស្ត្រសូក្រាត
- ការពិភាក្សាជាក្រុម
- ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

**ង. ការវាយតម្លៃ**

វិធីសាស្ត្រនៃការគ្រប់គ្រងចំណេះដឹង

**ច. ឯកសារ**

៥. អង្គការ DIHR, សេចក្តីផ្តើមនៃការបើកចំហ និងសិទ្ធិទទួលព័ត៌មាន

៦. អង្គការ មាត្រា ១៩, សិទ្ធិរបស់សាធារណៈជនដែលត្រូវដឹង, គោលការណ៍នៃ ច្បាប់ អំពី សិទ្ធិទទួលព័ត៌មាន

៧.អង្គការ API, មេរៀនទី ៨៖ គោលការណ៍ទាំង ៩ស្តីអំពីសិទ្ធិទទួលព័ត៌មាន(ខ្មែរ)

៨. Toby Mendel, សេរីភាពព័ត៌មាន, ការអង្កេតប្រៀបធៀបផ្នែកច្បាប់ (អង់គ្លេស ខ្មែរ), Unesco

**ឆ. ការសង្ខេបខ្លឹមសារមេរៀន**

១. គោលការណ៍ទី១៖ ការបើកចំហជាអតិបរិមា

- គោលការណ៍នេះកំណត់កាតព្វកិច្ចចំពោះអាជ្ញាធរ សាធារណៈក្នុងការបង្ហាញព័ត៌មានដែលគ្រប់គ្រងដោយ ពួកគេលើកណាដែលមានមូលហេតុនៃការលើកលែងដែលបានកំណត់ និងច្បាស់លាស់។

- គោលការណ៍នេះអាចហៅថា គោលការណ៍បើកចំហ ទូលាយ។

- អង្គភាពដែលមានកាតព្វកិច្ចបង្ហាព័ត៌មាន៖ អង្គភាព រដ្ឋាភិបាល និងរដ្ឋបាលទាំងអស់ឬ អាជ្ញាធរសាធារណៈ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

- ព័ត៌មានដែត្រូវបើកចំហត្រូវតែច្បាស់លាស់ និងមាន របៀបរៀបរយត្រឹមត្រូវដែលជួយ សម្រួលទាំងជនងាយ រងគ្រោះផង។

- រូបវន្តបុគ្គលឬនីតិបុគ្គលដែលបំពេញមុខងារសាធារណៈមានកាតព្វកិច្ចត្រូវបង្ហាញ ព័ត៌មានដែលកាន់កាប់ដោយ ពួកគេ។

- បុគ្គលគ្រប់រូបមានសិទ្ធិទទួលព័ត៌មានសាធារណៈហើយព័ត៌មានមិនមែនជាបុព្វសិទ្ធិរបស់ ក្រុមណាមួយ ទេ ដូចជាក្រុមអ្នកសារព័ត៌មានជាដើម។

- សៀវភៅណែនាំ ឬគោលការណ៍ណែនាំអំពីការទទួល ព័ត៌មានសម្រាប់សាធារណៈជន និងរបៀបប្រើប្រាស់វា គួរត្រូវរៀបចំឡើង។

- សិទ្ធិទទួលព័ត៌មានបុគ្គលៈ បុគ្គលគ្រប់រូប មានសិទ្ធិដឹង អំពីព័ត៌មាន ដែលអាជ្ញាធរសាធារណៈកត់ត្រាពីខ្លួន។ សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិកែតម្រូវនិងសុំលុបចោល ផងប្រសិនបើមានកំហុស។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ត្រូវមានការការពារភាពសំងាត់បុគ្គល និងចៀសវាង ការការប្រើប្រាស់ទិន្នន័យបុគ្គលដោយគ្មានការអនុញ្ញាតដែលធ្វើឲ្យខូចខាត ផលប្រយោជន៍បុគ្គល។

២. គោលការណ៍ទី២ៈ កាតព្វកិច្ចផ្សព្វផ្សាយជាសាធារណៈ

- អាជ្ញាធរសាធារណៈត្រូវផ្តល់ព័ត៌មានដល់សាធារណៈ ជនអំពីសកម្មភាពរបស់ខ្លួននិងព័ត៌មានដែលមាន ប្រយោជន៍សាធារណៈក្នុងវិស័យរបស់ខ្លួន។

- ព័ត៌មានដែលផ្តល់ជូនអាចកត់ត្រាតាមទម្រង់ណាមួយ របស់អាជ្ញាធរសាធារណៈដែលត្រូវបាន កត់ត្រា និង រក្សាទុកជាប្រព័ន្ធ និងត្រឹមត្រូវ ដូចជា តាមទម្រង់ជា ក្រដាស រូបថត ផែនទី ហ្វីល ម៉ាយក្រូឈីប ជាដើម។

- ព័ត៌មានដែលទទួលបានពីទម្រង់កត់ត្រាផ្សេងទៀតដូចជាព័ត៌មានផ្ទាល់មាត់អាចមានបញ្ហាប្រឈមក្នុង ការទទួលស្គាល់ថាតើជាព័តមានពិត ឬផ្លូវការ។

៣. គោលការណ៍ទី៣ៈ ការបើកស្នួយរដ្ឋាភិបាលឲ្យបើកចំហ

- អាជ្ញាធរសាធារណៈត្រូវជម្រុញវប្បធម៌បើកចំហយ៉ាងសកម្ម និងរដ្ឋាភិបាលបើកចំហទាំងខាង ក្នុងនិង ខាងក្រៅ។

- វិធានការជម្រុញការបើកចំហៈ តម្រូវឲ្យមានអ្នកដឹកនាំ ដែលមានការលះបង់។

- កម្មវិធីលើកកំពស់ការយល់ដឹងៈ កាតព្វកិច្ច ក្នុងការផ្សព្វ ផ្សាយ និងសិទ្ធិក្នុងការទទួលព័ត៌មាន។

- បង្កើតគោលការណ៍គណនេយ្យភាពដែលមានការទទួលខុសត្រូវច្បាស់លាស់

- បង្កើតប្រព័ន្ធគ្រប់គ្រងនិងរក្សាព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធនិងងាយស្រួលក្នុងការស្វែងរក។

៤. គោលការណ៍ទី៤ៈ ដែនកំណត់នៃការលើកលែង

- មូលហេតុនៃការលើកលែងចំពោះការបង្ហាញព័ត៌មាន ត្រូវតែកំណត់ឲ្យបានច្បាស់លាស់និងមានលក្ខណៈ ចង្អៀត។

- ការសន្មតជាមុនគឺការបើកចំហលើកលែងតែព័ត៌មានឆ្លើយតបនឹងលក្ខខណ្ឌ ៣ៈ

ក. ព័ត៌មានទាក់ទងនឹងផលប្រយោជន៍ស្របច្បាប់ដែល ការពារដោយច្បាប់។

ខ. ការបង្ហាញព័ត៌មានធ្វើឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ផលប្រយោជន៍ស្របច្បាប់ដែលការពារដោយច្បាប់នោះ។

គ. ការខូចខាតដល់ផលប្រយោជន៍ស្របច្បាប់ដែលការពារដោយច្បាប់ធំជាងផលប្រយោជន៍សាធារណៈក្នុងការទទួលព័ត៌មាន។

- ត្រូវមានតុល្យភាពរវាងផលប្រយោជន៍សាធារណៈ ក្នុងការផ្តល់ព័ត៌មាន និង ក្តីបារម្ភអំពីការគម្រាមកំហែងយ៉ាងធំដល់សុវត្ថិភាពរបស់ជាតិ និងផលប្រយោជន៍នៃ ភាពឯកជន។

- ព័ត៌មានដែលទាក់ទងនឹងផលប្រយោជន៍ស្របច្បាប់ដែលការពារដោយច្បាប់មានដូចជា ភាពឯកជនរបស់ បុគ្គល សុខភាព និងសុវត្ថិភាព ការអនុវត្តច្បាប់ ព័ត៌មាន ពាណិជ្ជកម្ម និង ព័ត៌មាន សំងាត់ ការការពារ ការធ្វើគោលនយោបាយ និងប្រតិបត្តិការ របស់ អាជ្ញាធរ សាធារណៈ និង សន្តិសុខជាតិ។

- ប្រសិនបើព័ត៌មានទាំងមូលមិនអាចបង្ហាញបានយ៉ាងហោចណាស់ក៏ព័ត៌មានមួយផ្នែកណាមួយត្រូវបង្ហាញដែរប្រសិនបើព័ត៌មាននោះមិនមែនស្ថិតក្នុងមូលហេតុលើកលែងទេ។

៥. គោលការណ៍ទី៥៖ ដំណើរការសម្របសម្រួលសិទ្ធិទទួល ព័ត៌មាន

- របៀបនៃការផ្តល់ព័ត៌មានត្រូវកំណត់និងបង្កើតឲ្យបាន ច្បាស់លាស់ដោយអាជ្ញាធរសាធារណៈ

i. ការផ្តល់ជំនួយដល់អ្នកស្នើដែលដាក់ពាក្យសុំព័ត៌មាន
ii. ការកំណត់ពេលវេលា
iii. ទម្រង់នៃការឆ្លើយតប
iv. ភាសា
v. មធ្យោបាយក្នុងការផ្តល់ព័ត៌មាន៖ ដោយការថតចម្លង ឯកសារ (ក្រដាស ឬ អេលិកត្រូនិក) ការពិនិត្យមើល កំណត់ត្រានៅនឹងកន្លែង ការធ្វើប្រតិចារិកពីសំណុំ ឯកសាយាន្តផ្ទុកព័ត៌មាន (កាស្សែត ស៊ីឌី) ការពន្យល់ផ្ទាល់មាត់ និងតាមទម្រង់ពិសេស នៃ សិទ្ធិទទួលព័ត៌មានរបស់ ជនពិការ ជាដើម។
vi. ហេតុផលនៃការបដិសេធនៃការផ្តល់ព័ត៌មាន
vii. ការបដិសេធនៃការផ្តល់ព័ត៌មានត្រូវមានការត្រួត ពិនិត្យដោយអង្គភាពឧបាស្រ័យ (សិទ្ធិឧបាស្រ័យរបស់ អ្នកស្នើសុំ)

- អង្គភាពគ្រប់គ្រង និងត្រួតពិនិត្យត្រូវបង្កើតឡើង ( ស្ថងការឬអង្គភាពព័ត៌មាន អំប៊ុដស៍មែន តុលាការ )។ នីតិវិធីនៃការត្រួតពិនិត្យត្រូវរៀបចំឡើងដើម្បីបង្កើតឲ្យមាន ការត្រួតពិនិត្យសេចក្តីសម្រេចរបស់ អាជ្ញាធរ សាធារណៈ។

៦. គោលការណ៍ទី៦៖ ការបង់ថ្លៃទទួលព័ត៌មាន

- ជាគោលការណ៍ ការផ្តល់ព័ត៌មានត្រូវធ្វើដោយឥតគិត ថ្លៃ។

- សិទ្ធិទទួលព័ត៌មានគឺជាសិទ្ធិ។ រាល់តម្លៃពាក់ព័ន្ធ ដែលអាជ្ញាធរត្រូវអនុវត្តសិទ្ធិនេះ ត្រូវចាត់ទុកជា ផ្នែក មួយនៃសេវាប្រចាំថ្ងៃ ដែលបានបង់ដោយប្រជាពលរដ្ឋ រួចហើយតាមរយៈពន្ធដា ជាដើម។

- តម្លៃនៃការថតចម្លងត្រូវតិចបំផុត និងមិនត្រូវជាឧបសគ្គ នៃសិទ្ធិទទួលព័ត៌មានឡើយ។

៧. គោលការណ៍ទី៧៖ កិច្ចប្រជុំបើកចំហ

- សេរីភាពនៃព័ត៌មានកំណត់ជាគោលការណ៍ថា រាល់កិច្ច ប្រជុំរបស់អង្គភាពរដ្ឋាភិបាលទាំងអស់ត្រូវបើកចំហ ជូន សាធារណៈជន ពីព្រោះសាធារណៈជនមានសិទ្ធិដឹងអ្វី ដែលរដ្ឋាភិបាលកំពុងធ្វើក្នុងនាមពួកគេ និង មានសិទ្ធិ ចូលរួមក្នុងការធ្វើសេចក្តីសម្រេច។

- កាតព្វកិច្ចក្នុងការឲ្យសាធារណៈជនចូលរួម បានកើន ឡើងក្នុងប្រទេសប្រជាធិបតេយ្យ។ ការចូលរួមអាចធ្វើ ដោយផ្ទាល់ឬ ប្រយោល។ ការចូលរួមដោយប្រយោល គឺការអញ្ជើញឲ្យចូលរួមប្រជុំសាធារណៈ ឬកិច្ចប្រជុំ បើកចំហ។ ការចូលរួមប្រជុំដោយផ្ទាល់ គឺការអញ្ជើញប្រជាពលរដ្ឋឲ្យចូលក្នុងគណមកម្មការ ( ករណី អស្សាមិករណ៍ )។

៨. គោលការណ៍ទី៨៖ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ត្រូវមាន ប្រៀបជាង

- គោលការណ៍ការបើកចំហជាអតិបរិមាត្រូវបានការពារ។

- ប្រសិនបើវប្បធម៌រក្សាការសម្ងាត់ត្រូវបានលើកឡើង ការបង្ហាញព័ត៌មានគឺត្រូវមានអាទិភាព។

- ក្នុងករណីច្បាប់ជាក់លាក់ណាមួយរបស់ប្រទេស មានទំនាស់ជាមួយច្បាប់នៃសិទ្ធិទទួលព័ត៌មាន នោះច្បាប់នៃសិទ្ធិទទួលព័ត៌មានមានអាទិភាពជាង។

៩. គោលការណ៍ទី៩៖ ការការពារប្រភពព័ត៌មាន

- អ្នកផ្តល់ព័ត៌មានចេញក្រៅគឺជាមន្ត្រីសាធារណៈ ដែល ទម្លាយព័ត៌មានសម្ងាត់អំពីកំហុសរបស់អាជ្ញាធរ សាធារណៈ។

- ប្រសិនបើអ្នកផ្តល់ព័ត៌មានចេញមកក្រៅធ្វើសកម្មភាពដោយសុចរិតនិងទៀងត្រង់ដើម្បប្រយោជន៍សាធារណៈ និងដើម្បីធានាការត្រួតពិនិត្យផ្ទៃក្នុងរបស់អាជ្ញាធរ សាធារណៈអ្នកផ្ត

ល់ព័ត៌មានចេញមកក្រៅនោះត្រូវបានការពាររួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនិង ការដាក់វិន័យ។

- ការការពារអ្នកផ្តល់ព័ត៌មានចេញមកក្រៅគឺដើម្បីធានាថាអំពើពុករលួយនិងកំហុសរបស់ អាជ្ញាធរសាធារណៈ អាចធ្វើឲ្យគេដឹងឮជាសាធារណៈ។

**ជ. សំណួរវាយតម្លៃការយល់ដឹង**

១.ចូរសរសេរអត្ថបទសាមញ្ញនិងខ្លីដែលពន្យល់សាធារណៈ ជនអំពីគោលការណ៍ទាំង៩នៃ សិទ្ធិទទួលព័ត៌មាន។

២. ចូរជ្រើសរើសច្បាប់ឬលិខិតបទដ្ឋានណាមួយដែលអ្នក ចាប់អារម្មណ៍(ប្រភពច្បាប់) ហើយរកមាត្រាដែលពាក់ព័ន្ធនឹង គោលការណ៍ ទាំង៩នៃសិទ្ធិទទួលព័ត៌មាន។

## ជំពូកទី ៥
## ការត្រួតពិនិត្យច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅកម្ពុជា (១)

### ក. គោលបំណង

ណែនាំនិស្សិតអំពីការរកឃើញសំខាន់ៗនៃសិទ្ធិទទួលព័ត៌មាននៅកម្ពុជា(១)និងការសរសេររបាយការណ៍ (១)

### ខ. លទ្ធផលនៃការសិក្សា

- ការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ននៃសិទ្ធិទទួលព័ត៌មាននៅកម្ពុជា
- សិទ្ធិទទួលព័ត៌មាននៅក្នុងវិស័យផ្សេងៗដូចជា វិស័យអប់រំ សុខភាព សេដ្ឋកិច្ច និងការងារ
- វិធីសាស្ត្រនៃការសរសេររបាយការណ៍

### គ. មាតិកា

១. សិទ្ធិទទួលព័ត៌មានក្នុងវិស័យអប់រំ
២. សិទ្ធិទទួលព័ត៌មានក្នុងវិស័យសុខភាព
៣. សិទ្ធិទទួលព័ត៌មានក្នុងវិស័យសេដ្ឋកិច្ចនិងវិនិយោគ
៤. សិទ្ធិទទួលព័ត៌មានក្នុងវិស័យការងារ
៥. ការសរសេររបាយការណ៍ (១)
៦. ឈប់និងត្រួតពិនិត្យ

### ឃ. វិធីសាស្ត្រនៃការបង្រៀន

- លំហាត់នៃការណែនាំខ្លួន
- វិធីសាស្ត្រសូក្រាត
- ការពិភាក្សាជាក្រុម
- ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

### ង. ការវាយតម្លៃ

វិធីសាស្ត្រនៃការគ្រប់គ្រងចំណេះដឹង

### ច. ឯកសារ

៩. អង្គការ API, របកគំហើញនៃការពិនិត្យនិងការវិភាគឯកសារ ច្បាប់និងអនុក្រិត្យដែលមានចែង អំពីសិទ្ធិទទួលព័ត៌មាននិងការបើកចំហ ព័ត៌មាន៖ អប់រំ សុខភាពនិងឪសថ, សេដ្ឋកិច្ចនិងវិនិយោគ, ការងារ, បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, រ៉ែមជ្ឈការនិង វិសហមជ្ឈការ, កសិកម្ម ជលផល និងរុក្ខប្រមាញ់, ពិការភាព និងរដ្ឋបាលសាធារណៈ

១០. ក្របខណ្ឌគោលនយោបាយស្តីអំពីសិទ្ធិទទួល ព័ត៌មាន (សេចក្តីព្រាង)

### ឆ. ការសង្ខេបខ្លឹមសារមេរៀន

១. សេចក្តីផ្តើម

- ប្រទេសកម្ពុជាមិនទាន់មានច្បាប់ស្តពីសិទ្ធិទទួលព័ត៌មាន ទេ។បច្ចុប្បន្ននេះ ក្រសួងព័ត៌មានកំពុងរៀបចំច្បាប់ នេះ។

- សេចក្តីព្រាងក្របខណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានរៀបចំឡើងនៅឆ្នាំ ២០០៧ ប៉ុន្តែមកទល់ពេល នេះមិនទាន់បានអនុមតិទេ។ សេចក្តី ព្រាងក្របខណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មានបានបញ្ចូលគោលការណ៍ទាំង៩ ហើយដាក់ឲ្យមាន ការពិគ្រោះយោបល់នៅឆ្នាំ ២០០៧ និងអាចជា ឧបករណ៍ណែនាំមួយសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។

២. សិទ្ធិទទួលព័ត៌មានក្នុងវិស័យអប់រំ

- ការសិក្សាលើច្បាប់ចំនួន ៥ និងអនុក្រិត្យ ៣២ បង្ហាញ ថាគោលការណ៍នៃសិទ្ធិទទួលព័ត៌មានបានបញ្ចូលក្នុងច្បាប់ប៉ុន្តែមិនមានទាំងអស់ទេ។

៣. សិទ្ធិទទួលព័ត៌មានក្នុងវិស័យសុខភាព

- ការសិក្សាលើច្បាប់ចំនួន ២៩ និងអនុក្រិត្យ ២៧ បង្ហាញថាច្បាប់ខ្លះមានខ្លឹមសារទាក់ទងនឹង គោល ការណ៍ទាំង ៩នៃសិទ្ធិទទួលព័ត៌មាន ដូចជា គោល ការណ៍នៃ ការបង្ហាញព័ត៌មាន ដល់ សាធារណៈជន និងការជម្រុញឲ្យមានរដ្ឋាភិបាលបើកចំហ។

៤. សិទ្ធិទទួលព័ត៌មានក្នុងវិស័យសេដ្ឋកិច្ចនិងវិនិយោគ

- ការសិក្សាលើច្បាប់ចំនួន ៩៧ និងអនុក្រិត្យ ១១៣ បង្ហាញថាច្បាប់ចំនួន ៧០% និងអនុក្រិត្យចំនួន ៦០% មានចែងជាក់លាក់អំពីគោលការណ៍សំខាន់ៗនៃ សិទ្ធិ ទទួលព័ត៌មាន ដូចជា ការបង្ហាញព័ត៌មាន រដ្ឋាភិបាលបើកចំហ និងដំណើរការនៃការសម្រួលព័ត៌មាន ។

៥. សិទ្ធិទទួលព័ត៌មានក្នុងវិស័យការងារ

- ការសិក្សាលើច្បាប់ចំនួន ១៩ និងអនុក្រិត្យ ១១ បង្ហាញថា មានច្បាប់តែ ១និងអនុក្រិត្យចំនួន ២ប៉ុណ្ណោះ ដែលមានបទប្បញ្ញត្តិ ទាក់ទងនឹងការបង្ហាញព័ត៌មាន។
- ច្បាប់ការងារមាន ចំនួន ១៣ មាត្រាដែលទាក់ទងនឹង សិទ្ធិទទួលព័ត៌មាន និងមានបទប្បញ្ញត្តិទាក់ទងនឹង ការការពារព័ត៌មានសំងាត់។
- អនុក្រិត្យលេខ ១១៧ចុះថ្ងៃទី ១៣ ខែកញ្ញាឆ្នាំ ២០០៩ និង អនុក្រិត្យលេខ ៦៧ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០០៩ជម្រុញឲ្យមានការនង្ហាញព័ត៌មានដល់អ្នកស្វែង រកការងារធ្វើ អ្នកធ្វើគោលនយោបាយ ទិផ្សារការងារជាមដើម។

៦. ការសរសេររបាយការណ៍ (១)

- ការសរសេរនិងវិភាគច្បាប់
- ហេតុអ្វីត្រូវសរសេរ?
- សរសេរសម្រាប់អ្នកណា?
- ចាប់ផ្តើមដូចម្តេច?
- ក្រមសីលធម៌វិជ្ជាជីវៈរបស់អ្នកសរសេរ

## ជ. សំណួរវាយតម្លៃការយល់ដឹង

១. ចូរពិនិត្យរបាយការណ៍តាមវិស័យនិងសរសេរឡើងវិញដើម្បីជម្រាបដល់សាធារណៈជន អំពីច្បាប់និងបញ្ញត្តិច្បាប់ បច្ចុប្បន្ននៅប្រទេសកម្ពុជាដែលមានបទប្បញ្ញត្តិទាក់ទងនឹង សិទ្ធិទទួលព័ត៌មាន

២. ចូរធ្វើការសិក្សាដោយខ្លួនឯងអំពីច្បាប់និងបញ្ញត្តិច្បាប់ ពីឆ្នាំ ២០១៤ ដល់ ២០១៥ដោយប្រើប្រាស់គោលការណ៍ទាំង៩ នៃសិទ្ធិទទួលព័ត៌មាន ដើម្បីវាយតម្លៃ ច្បាប់និង បញ្ញត្តិច្បាប់នោះ។

# ជំពូកទី ៦
# ការត្រួតពិនិត្យច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅកម្ពុជា (២)

## ក. គោលបំណង

ណែនាំនិស្សិតអំពីការរកឃើញសំខាន់ៗនៃសិទ្ធិទទួលព័ត៌មាននៅកម្ពុជា(២)និងការសរសេររបាយការណ៍ (២)

## ខ. លទ្ធផលនៃការសិក្សា

- ការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ននៃសិទ្ធិទទួលព័ត៌មាននៅកម្ពុជា
- សិទ្ធិទទួលព័ត៌មាននៅក្នុងវិស័យផ្សេងៗដូចជាវិស័យបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ វិមជ្ឈការ និងវិសហមជ្ឈការ កសិកម្ម ពិការភាព និងរដ្ឋបាលសាធារណៈ
- សំណើរបាយការណ៍ស្រាវជ្រាវត្រូវបានបង្កើត

## គ. មាតិកា

១. សិទ្ធិទទួលព័ត៌មានក្នុងវិស័យបរិស្ថាន និងការគ្រប់គ្រង ធនធាន ធម្មជាតិ

២. សិទ្ធិទទួលព័ត៌មានក្នុងវិស័យវិមជ្ឈការ និងវិសហមជ្ឈការ

៣. សិទ្ធិទទួលព័ត៌មានក្នុងវិស័យកសិកម្ម ជលផល និង រដ្ឋបាលព្រៃឈើ

៤. សិទ្ធិទទួលព័ត៌មានក្នុងវិស័យពិការភាព

៥. សិទ្ធិទទួលព័ត៌មានក្នុងវិស័យរដ្ឋបាលសាធារណៈ

៦. ការសរសេររបាយការណ៍ (២)

៧. ឈប់និងត្រួតពិនិត្យ

## ឃ. វិធីសាស្រ្តនៃការបង្រៀន

- លំហាត់នៃការណែនាំខ្លួន
- វិធីសាស្រ្តសូក្រាត
- ការពិភាក្សាជាក្រុម

- ការស្រាវជ្រាវ និង ការធ្វើបទបង្ហាញ

**ង. ការវាយតម្លៃ**

វិធីសាស្ត្រនៃការគ្រប់គ្រងចំណេះដឹង

**ច. ឯកសារ**

៩. អង្គការ API, របកគំហើញនៃការពិនិត្យនិងការវិភាគឯកសារ ច្បាប់និងអនុក្រិត្យដែលមានចែង អំពីសិទ្ធិទទួលព័ត៌មាននិងការបើកចំហ ព័ត៌មាន៖ អប់រំ សុខភាពនិងឳសថ, សេដ្ឋកិច្ចនិងវិនិយោគ, ការងារ, បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, រ៉ែមជ្ឈការនិង វិសហមជ្ឈការ, កសិកម្ម ជលផល និងរុក្ខប្រមាញ់, ពិការភាព និងរដ្ឋបាលសាធារណៈ

១០. ក្របខណ្ឌគោលនយោបាយស្តីអំពីសិទ្ធិទទួល ព័ត៌មាន (សេចក្តីព្រាង)

**ឆ. ការសង្ខេបខ្លឹមសារមេរៀន**

១. សិទ្ធិទទួលព័ត៌មានក្នុងវិស័យបរិស្ថាន និងការគ្រប់គ្រង ធនធាន ធម្មជាតិ

- ការសិក្សាលើច្បាប់ចំនួន ៨ និងអនុក្រិត្យ ៤៥ បង្ហាញ ថា មានបទប្បញ្ញត្តិ ទាក់ទងនឹងការបង្ហាញព័ត៌មាន ដល់សាធារណៈជន និងការពិគ្រោះយោបល់ជាមួយ សាធារណៈជន។

២. សិទ្ធិទទួលព័ត៌មានក្នុងវិស័យវិមជ្ឈការ និងវិសហមជ្ឈការ

- ការសិក្សាលើច្បាប់ចំនួន ៩ និងអនុក្រិត្យ ២៣ បង្ហាញ ថា មានតែច្បាប់ ៦ និងអនុក្រិត្យ ២៧ ប៉ុណ្ណោះដែល មានបទប្បញ្ញត្តិ ទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន ដូចជា សិទ្ធិរបស់សាធារណៈជនក្នុងការទទួលព័ត៌មាន កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មាន និង ការពិគ្រោះ យោបល់។

៣. សិទ្ធិទទួលព័ត៌មានក្នុងវិស័យកសិកម្ម ជលផល និង រដ្ឋបាលព្រៃឈើ

- ការសិក្សាលើច្បាប់និងអនុក្រិត្យ បង្ហាញថា មាន បទប្បញ្ញត្តិ ទាក់ទងនឹង ជូនដំណឹងជាសាធារណៈ សិទ្ធិទទួលព័ត៌មានរបស់សាធារណៈជន និងការចូល រួមក្នុងការដេញថ្លៃ។

៤. សិទ្ធិទទួលព័ត៌មានក្នុងវិស័យពិការភាព

- ការសិក្សាលើច្បាប់និងអនុក្រិត្យបង្ហាញថាព័ត៌មានត្រូវផ្តល់ ដោយឥតគិតថ្លៃ និងមានបទប្បញ្ញត្តិ ពីការបង្ហាញ ព័ត៌មាន។

៥. សិទ្ធិទទួលព័ត៌មានក្នុងវិស័យរដ្ឋបាលសាធារណៈ

- ការសិក្សាលើច្បាប់ចំនួន ៤៩ និងអនុក្រិត្យ ១៤៩ បង្ហាញថាការបង្ហាញព័ត៌មានមានលក្ខណៈទូលាយ។ មានតែច្បាប់ ២៣ក្នុងចំណោមច្បាប់៤៩ និងអនុក្រិត្យ ៣៩ ក្នុងចំណោម ១៤៩ប៉ុណ្ណោះដែលមានបទប្បញ្ញត្តិ ទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន។

៦. ការសរសេររបាយការណ៍ (២)

- ការបង្កើតគម្រោងស្រាវជ្រាវ

## ជ. សំណួរវាយតម្លៃការយល់ដឹង

១. ចូរពិនិត្យរបាយការណ៍តាមវិស័យនិងសរសេរឡើងវិញ ដើម្បីជម្រាបដល់សាធារណៈជន អំពីច្បាប់និងបញ្ញត្តិច្បាប់ បច្ចុប្បន្ននៅប្រទេសកម្ពុជាដែលមានបទប្បញ្ញត្តិទាក់ទងនឹង សិទ្ធិទទួលព័ត៌មាន។

២. ចូរធ្វើការសិក្សាដោយខ្លួនឯងអំពីច្បាប់និងបញ្ញត្តិច្បាប់ ពីឆ្នាំ ២០១៤ ដល់ ២០១៥ ដោយប្រើប្រាស់គោលការណ៍ទាំង៩ នៃសិទ្ធិទទួលព័ត៌មាន ដើម្បីវាយតម្លៃ ច្បាប់និង បញ្ញត្តិច្បាប់នោះ។

# ឧបសម្ព័ន្ធ

## ១.ឯកសារយោង

- អត្ថបទ៖ទិដ្ឋភាពទូទៅនៃប្រព័ន្ធច្បាប់និងតុលាការប្រទេសកម្ពុជា ដោយ គង់ ផល្លៈ
- សៀវភៅ៖ សេចក្តីផ្តើមនៃនីតិកម្ពុជា (Kas' s Publication)
- រដ្ឋធម្មនុញ្ញកម្ពុជា
- សន្ធិសញ្ញាអន្តរជាតិដែលផ្តល់សច្ចាប័នដោយកម្ពុជា
- អង្គការ DIHR, សេចក្តីផ្តើមនៃការបើកចំហ និងសិទ្ធិទទួលព័ត៌មាន
- អង្គការ មាត្រា ១៩, សិទ្ធិរបស់សាធារណៈជនដែលត្រូវដឹង, គោលការណ៍នៃ ច្បាប់អំពីសិទ្ធិទទួលព័ត៌មាន
- អង្គការ API, មេរៀនទី ៨៖ គោលការណ៍ទាំង ៩ស្តីអំពីសិទ្ធិទទួលព័ត៌មាន(ខ្មែរ)
- Toby Mendel, សេរីភាពព័ត៌មាន, ការអង្កេតប្រៀបធៀបផ្នែកច្បាប់ (អង់គ្លេស ខ្មែរ), Unesco
- អង្គការ API, របកគំហើញនៃការពិនិត្យនិងការវិភាគឯកសារច្បាប់និងអនុក្រិត្យដែលមានចែងអំពីសិទ្ធិទទួលព័ត៌មាននិងការបើកចំហព័ត៌មាន៖ អប់រំ សុខភាពនិងឪសថ, សេដ្ឋកិច្ចនិងវិនិយោគ, ការងារ, បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, រ៉ែម៉ជ្ឈការនិង វិសហមជ្ឈការ, កសិកម្ម ជលផល និងរុក្ខប្រមាញ់, ពិការភាព និងរដ្ឋបាលសាធារណៈ
- ក្របខណ្ឌគោលនយោបាយស្តីអំពីសិទ្ធិទទួលព័ត៌មាន (សេចក្តីព្រាង)

*ឯកសារគោលស្តីពី **សិទ្ធិទទួលព័ត៌មាន***
*រៀបរៀងដោយសាស្ត្រាចារ្យ បណ្ឌិត គង់ ផល្លៈ*
*បោះពុម្ពដោយវិទ្យាស្ថានសារគមនាគន៍កម្ពុជា*
*នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ*
*ខែសីហា ឆ្នាំ២០១៦*